# គ្រូអប់រំក្រៅប្រព័ន្ធ

*តើអ្នកមានចំណាប់អារម្មណ៍ធ្វើការងារជាមួយកុមារ យុវវ័យ ដែលបាត់បង់ឱកាស ដើម្បីបំប៉នចំណេះដឹងពួកគេអាចបន្តការសិក្សានៅសាលារដ្ឋដែរឬទេ? តើអ្នកចង់ធ្វើការជាមួយក្រុមអ្នកជំនាញ ដែលផ្តល់នូវសេវាកម្មសង្គមជាច្រើនដល់សហគមន៍ នៅរាជធានីភ្នំពេញដែរឬទេ? ប្រសិនមានមានចំណាប់អារម្មណ៍ សូមប្រញាប់មកដាក់ពាក្យនៅអង្គការមិត្តសំឡាញ់។*

អ្នកនឹងចូលរួមជាមួយក្រុមការងាររបស់អង្គការមិត្តសំឡាញ់ ដែលមានអ្នកជំនាញជាង២០០នាក់ ធ្វើការជាមួយគ្នា ដើម្បីផ្តល់នូវសេវាសង្គមជាច្រើនទៅដល់កុមារ និងយុវវ័យដែលបាត់បង់ឱកាស និងក្រុមគ្រួសាររបស់ពួកគេ។ យើងបានបង្កើតវិធីសាស្ត្ររួមមួយចំនួន ដើម្បីគាំទ្រឲ្យកុមារត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារ និងបន្តការសិក្សារបស់ពួកគេវិញ ធានាក្នុងការផ្តល់ការបណ្តុះបណ្តាលជំនាញ ឬការងារទៅដល់យុវវ័យ រួមទាំងការគាំទ្រគ្រួសារ និងសហគមន៍ ក្នុងការជួយថែទាំកូនរបស់គាត់។ យើងបានផ្តល់ការបណ្តុះបណ្តាលដល់យុវជនលើជំនាញជាច្រើនដូចជា ចុង ភៅ សេវាកម្ម ជួសជុលម៉ូតូ សម្អាងកាយ ជាងកាត់សក់ ជាងផ្សា ផ្នែកអគ្គិសនី ផ្នែកកាត់ដេរ និងការបណ្តុះបណ្តាលដើម្បីបង្កើតចំណូលដល់អាណាព្យាបាល។

**តើអ្នកត្រូវធ្វើអ្វីខ្លះ?**

តួនាទីជា **គ្រូអប់រំក្រៅប្រព័ន្ធ** អ្នកនឹងទទួលខុសត្រូវ ក្នុងការបង្រៀនថ្នាក់បំប៉នដល់កុមារ នៅតាមសហគមន៍ ដើម្បីឲ្យគាត់មានចំណេះសមល្មមអាចនឹងបន្តការសិក្សានៅសាលារដ្ឋបាន។

**អ្នកនឹងទទួលខុសត្រូវដូចខាងក្រោម:**

- បង្រៀនសិស្សថ្នាក់អប់រំក្រៅប្រព័ន្ធ និងថ្នាក់បំប៉នត្រឹមកំរិតបឋមសិក្សា
- ផលិត និងរៀបចំសម្ភារ:ឧបទ្ទេសសម្រាប់បង្រៀនសិស្ស
- សហការជាមួយអណាព្យាបាល អជ្ញាធរដែនដី និងបុគ្គលិកសង្គម ដើម្បីធ្វើសមាហរណកម្មកុមារទៅសាលារដ្ឋ
- តាមដាន និងវាយតម្លៃការសិក្សារបស់សិស្ស
- បង្កើតទំនាក់ទំនងល្អជាមួយអាណាព្យាបាលសិស្ស
- ផ្តល់ការគាំទ្រកុមារ/យុវវ័យ និងក្រុមគ្រួសារទៅកាន់សេវាផ្សេងៗ
- តាមដានការសិក្សាសិស្សសាលារដ្ឋ

**ល័ក្ខខ័ណ្ឌនៃការជ្រើសរើស:**

- មានសញ្ញាប័ត្រទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍បង្រៀនសិស្សយ៉ាងតិច ១ឆ្នាំ
- មានជំនាញក្នុងការទំនាក់ទំនង ពិគ្រោះយោបល់ និងធ្វើការងារជាក្រុម
- មានចំណេះដឹងផ្នែកសង្គមសាស្ត្រ និងចិត្តសាស្ត្រ កាន់តែប្រសើរ
- មានភាពអំណត់, ភាពរហ័សរហួន និងមានឆន្ទះក្នុងការធ្វើការជាមួយកុមារ/ យុវវ័យបាត់បង់ឱកាស
- អាចបត់បែនទៅតាមស្ថានភាព និងពេលវេលា

បេក្ខជនដែលមានចំណាប់អារម្មណ៍ និងគុណសម្បត្តិគ្រប់គ្រាន់ សូមផ្ញើពាក្យសុំ និងប្រវត្តិរូបសង្ខេប (CV and Cover Letter) មកកាន់ទីស្នាក់ការអង្គការមិត្តសំឡាញ់ តាមអាសយដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ (ខាងជើងសារមន្ទីរជាតិ) ឬ០២៣ ២២០ ៥៩៦ ឬ E-mail: hr@mithsamlanh.org។ **សូមបញ្ជាក់ពីប្រាក់បៀវត្សរ៍រំពឹងទុក និងតួនាទី ដែលអ្នកដាក់ពាក្យ។**

ការជ្រើសរើសនឹងត្រូវបានធ្វើឡើងប្រកបដោយតម្លាភាព។

បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹង ត្រូវបានទំនាក់ទំនងមកធ្វើការសម្ភាសន៍។ បេក្ខជនដែលជោគជ័យនឹងត្រូវបានតម្រូវឲ្យ គោរពតាមគោលការណ៍ ការពារកុមាររបស់អង្គការមិត្តសំឡាញ់។

**ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។**